សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា

Cambodian Journalists Alliance Association



# របាយការណ៍ឃ្លាំមើលប្រចាំត្រីមាសស្តីពី

# ស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជា

ខែកក្កដា - កញ្ញា ឆ្នាំ២០២៣ | លេខចេញផ្សាយ ០៩



# មាតិកា


១. សេចក្តីផ្តើម និងសេចក្តីសង្ខេប........................................ ៤

២. និយមន័យនៃពាក្យគន្លឹះ.................................................. ៨

៣. បរិបទក្នុងត្រីមាសនេះ................................................... ៩

៤. ឧប្បត្តិហេតុរាយការណ៍ក្នុងត្រីមាសនេះ..................................... ១១

៥. ការធ្វើបច្ចុប្បន្នភាពសំខាន់ៗ............................................. ២៣

៦. ករណីសិក្សា៖ រដ្ឋាភិបាលបញ្ជាឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិតពាំង គេហទំព័រកំណត់ត្រា.................................................. ២៥

៧. ករណីសិក្សា៖ បញ្ហាប្រឈមរបស់ស្ថាប័នសារព័ត៌មានឯករាជ្យ និងអ្នកសារព័ត៌មាននៅកម្ពុជា........................................ ២៨

៨. ប្រវត្តិនៃការរឹតត្បិតតាមអនឡាញនៅកម្ពុជា................................ ៣០

# សេចក្តីផ្តើម និង សេចក្តីសង្ខេប

ខណៈដែលរដ្ឋាភិបាលកម្ពុជា ឈានទៅរកការគ្រប់គ្រង និង ឃ្លាំមើល តាមប្រព័ន្ធផ្សព្វផ្សាយ ទាំងផ្នែកបោះពុម្ព និង តាមអនឡាញ អត្រានៃការយាយី និង ការបំភិតបំភ័យទៅលើអ្នកសារព័ត៌មាន បានដាក់កំហិតយ៉ាងខ្លាំងទៅលើសេរីភាព និង សុវត្ថិភាពរបស់អ្នកសារព័ត៌មាន ដោយរារាំងពួកគេក្នុងការរាយការណ៍ព័ត៌មានដោយសេរី និង ដោយគ្មានការភ័យខ្លាចនឹងការសងសឹក។

អ្នកសារព័ត៌មាននៅកម្ពុជា ទទួលរងការយាយី និង ការគំរាមកំហែងទាំងមកលើខ្លួនពួកគេ និង អង្គភាពសារព័ត៌មានរបស់ពួកគេ។ វាចាំបាច់ណាស់ក្នុងការកត់ត្រាករណីទាំងនេះ ដើម្បីទាញយកការយកចិត្តទុកដាក់ចំពោះបញ្ហានេះ។

របាយការណ៍ប្រចាំត្រីមាសរបស់ខេមបូចា ដើរតួនាទីជាឧបករណ៍សំខាន់ក្នុងការកត់ត្រានិងវាយតម្លៃនិន្នាការនានា ព្រឹត្តិការណ៍ វិវឌ្ឍន៍ថ្មីៗក្នុងស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជា។ វាគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងបន្តរបស់យើងក្នុងការឃ្លាំមើល និង តស៊ូមតិដើម្បីសេរីភាពសារព័ត៌មាននៅកម្ពុជា។ វារួមបញ្ចូលសេចក្តីសង្ខេបខ្លីៗនៃឧប្បត្តិហេតុ និង បច្ចុប្បន្នភាពព័ត៌មានថ្មីៗទាក់ទងនឹងសេរីភាពសារព័ត៌មាន និង សេរីភាពនៃការបញ្ចេញមតិ ក្នុងអំឡុងពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ ២០២៣។

សេរីភាពសារព័ត៌មាន គឺជាមូលដ្ឋានគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ។ ប្រព័ន្ធផ្សព្វផ្សាយ និង អ្នកសារព័ត៌មានឯករាជ្យ ដើរតួជាអ្នកឃ្លាំមើល ដោយជំរុញឲ្យអ្នកដែលមានអំណាចមានការទទួលខុសត្រូវ លើកកម្ពស់តម្លាភាព និង លើកទឹកចិត្តឱ្យមានលំហូរព័ត៌មានដោយសេរីដែលចេញពីទស្សនៈចម្រុះ។ សេរីភាពសារព័ត៌មានផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋ ដោយផ្តល់ឲ្យពួកគេនូវព័ត៌មានត្រឹមត្រូវ និង គួរឲ្យទុកចិត្តបាន។

ក្នុងត្រីមាសនេះ មុនការបោះឆ្នោតជាតិនាខែកក្កដា ឆ្នាំ២០២៣ អ្នកសារព័ត៌មានបានប្រឈមមុខនឹងរលកថ្មីនៃការយាយី បើធៀបនឹងត្រីមាសមុនៗ។ យើងបានចងក្រងកត់ត្រាអ្នកសារព័ត៌មាន យ៉ាងហោចណាស់ ១០នាក់ ដែលត្រូវបានអាជ្ញាធរកំណត់ជាគោលដៅនៅថ្ងៃបោះឆ្នោត គឺបន្ថែមទៅលើឧប្បត្តិហេតុជាច្រើនទៀត ដែលប៉ះពាល់ដល់សេរីភាពសារព័ត៌មានដែលកើតឡើងពេញមួយត្រីមាស។

ព្រឹត្តិការណ៍វិវឌ្ឍន៍ថ្មីសំខាន់ៗដែលយើងបានកត់ត្រានិងឃ្លាំមើលក្នុងអំឡុងត្រីមាសនេះគឺជាការកើនឡើងនៃការយាយី និង ការបន្តចេញបទបញ្ជារបស់រដ្ឋាភិបាលទៅកាន់អ្នកផ្តល់សេវាអ៊ីនធឺណិត ដើម្បីបិទការចូលមើលប្រព័ន្ធផ្សព្វផ្សាយអនឡាញជាច្រើនមុនពេល និង អំឡុងពេលការបោះឆ្នោត។ លើសពីនេះទៅទៀត ខេមបូចា បានរាយការណ៍ព័ត៌មាន ពីការដោះលែងអ្នកសារព័ត៌មានម្នាក់នៅខេត្តបាត់ដំបង បន្ទាប់ពីជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ និង ការបង្កើតគណកម្មាធិការជាតិសម្របសម្រួលកិច្ចការព័ត៌មាន និង សាធារណមតិ។

ត្រីមាសនេះ ដែលចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៣ ខេមបូចា បានកត់ត្រាករណីយាយីចំនួន៩ ករណី ទៅលើអ្នកសារព័ត៌មានចំនួន ១៤នាក់ (ក្នុងនោះស្រី ២ នាក់) ហើយមានស្ថាប័នសារព័ត៌មានចំនួនបីត្រូវបានបិទគេហៈទំព័រ។

ត្រីមាសនេះឃើញមានការកើនឡើងនៃការរឹតត្បិតទៅលើបណ្តាញប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ជាពិសេស បន្ទាប់ពីមានការបិទ វីអូឌី (VOD) ។ នៅមុនការបោះឆ្នោត ក៏ដូចជានៅថ្ងៃបោះឆ្នោត ក៏ឃើញមានករណីយាយីកើនឡើងយ៉ាងគំហុកទៅលើអ្នកសារព័ត៌មាន ដោយសារតែអាជ្ញាធរ និង អ្នកផ្សេងទៀត បានព្យាយាមរាំងអ្នកសារព័ត៌មានមិនឲ្យយកព័ត៌មាន។

យើងមានគោលបំណង ទទួលស្គាល់ កត់ត្រា និង ដោះស្រាយគ្រោះថ្នាក់ដែលអ្នកសារព័ត៌មានប្រឈមមុខតាមរយៈរបាយការណ៍នេះ។ អ្នកសារព័ត៌មានមានសិទ្ធិធ្វើការដោយគ្មានការភ័យខ្លាច។ នៅពេលដែលលោកអ្នកអានរបាយការណ៍នេះ យើងលើកទឹកចិត្តលោកអ្នកឱ្យឆ្លុះបញ្ចាំងពីស្ថានភាពអ្នកសារព័ត៌មាននៅកម្ពុជា និង សារៈសំខាន់នៃសេរីភាពសារព័ត៌មាន។

# សេចក្តីសង្ខេបឧប្បត្តិហេតុនៃការយាយីទៅលើ អ្នកសារព័ត៌មានពីខែកក្កដា ដល់ខែកញ្ញា



សុវត្ថិភាពផ្លូវកាយ

0ករណី នៃការវាយប្រហារឧបករណ៍និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន



ការវាយប្រហារឧបករណ៍និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន

0ករណី នៃហឹង្សាលើរូបរាងកាយ



ហឹង្សាលើរូបរាងកាយ

៦ករណី អ្នកសារព័ត៌មាន១០នាក់



ការគំរាមកំហែងដោយពាក្យសម្តី



សុវត្ថិភាពអនឡាញ

១ករណី ៣គេហទំព័រ



បិទគេហទំព័រ

០ករណី នៃការបៀតបៀនផ្លូវភេទតាមអនឡាញ



ការបៀតបៀនផ្លូវភេទតាមអនឡាញ

០ករណី នៃការបៀតបៀនតាមអនឡាញ



ការបៀតបៀនតាមអនឡាញ



សុវត្ថិភាពផ្លូវច្បាប់

២ករណី ប៉ះពាល់ អ្នកសារព័ត៌មាន៤នាក់




ការបំភិតបំភ័យតាមផ្លូវច្បាប់

# ទីកន្លែងឧប្បត្តិហេតុ





# និយមន័យនៃពាក្យគន្លឹះ

## ពាក្យគន្លឹះមួយចំនួនដែលប្រើក្នុងរបាយការណ៍នេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**អ្នកសារព័ត៌មាន** *រួមមានបុគ្គលិកសារព័ត៌មាន ដូចជា អ្នកយកព័ត៌មាន អ្នកសារព័ត៌មានសេរី អ្នកសារព័ត៌មានថតរូប អ្នកសារព័ត៌មានពលរដ្ឋ បុគ្គលិកជំនួយ និង អ្នកផ្សេងទៀតដែលកាន់បណ្ណសារព័ត៌មានចេញដោយក្រសួងព័ត៌មាន ឬកាន់កាតសម្គាល់ខ្លួនចេញដោយអង្គភាពរបស់ខ្លួន។ គេមិនរាប់បញ្ចូលអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដោយគ្មានលិខិតបញ្ជាក់វិជ្ជាជីវៈទាំងនេះទេ។*

**ករណីយាយី** *គ្របដណ្ដប់លើការវាយប្រហារគ្រប់ប្រភេទ រាប់ចាប់ពីអំពើហិង្សារហូតដល់ការគំរាមកំហែង ការចាប់ខ្លួន ការចាប់ដាក់ពន្ធនាគារ ចំណាត់ការផ្លូវច្បាប់ និង ការលុបអាជ្ញាបណ្ណ។*

**ចំណាត់ការផ្លូវច្បាប់** *មានន័យថា សកម្មភាពផ្លូវច្បាប់ ឬតុលាការប្រឆាំងនឹងអ្នកសារព័ត៌មាន រួមមានបណ្ដឹង និង ការកោះហៅមកសាកសួរជាដើម។*

**ការលុបអាជ្ញាបណ្ណ** *មានន័យថា ក្រសួងព័ត៌មានបានដកហូតអាជ្ញាបណ្ណ ជាផ្លូវការពីអង្គភាពផ្សព្វផ្សាយណាមួយ។*

**អំពើហិង្សា** *សំដៅលើអំពើហិង្សាលើរាងកាយ និង ការគំរាមកំហែងប្រើអំពើហិង្សាលើរាងកាយ។*

**ការបំភិតបំភ័យ** *សំដៅលើករណីដែលអាជ្ញាធរបានគំរាមកំហែងចាប់ខ្លួន ចំណាត់ការផ្លូវច្បាប់ ឬវិធានការផ្សេងទៀត ក្នុងគោលបំណងរារាំងមិនឲ្យផ្សព្វផ្សាយព័ត៌មាន ឬហាមឃាត់អ្នកសារព័ត៌មានមិនឲ្យចូលយកព័ត៌មាន។*

**ការរើសអើង** *សំដៅលើករណីដែលមន្ត្រី ឬអង្គការនានាដែលបានកំណត់យកអង្គភាពផ្សព្វផ្សាយឯករាជ្យសម្រាប់ការប្រព្រឹត្តផ្សេងគ្នាពីអង្គភាពដទៃ ឬរារាំងមិនឲ្យចូលយកព័ត៌មានចំពោះអ្នកសារព័ត៌មានដែលគេគិតថារិះគន់រដ្ឋាភិបាល។*

**ការឃុំខ្លួន** *មានន័យថាឃុំខ្លួនដើម្បីសាកសួរពីរបីម៉ោង ឬពេញមួយយប់ ប៉ុន្តែមិនមានការចោទប្រកាន់ និង ដាក់ពន្ធនាគារទេ។*

**ការដាក់ពន្ធនាគារ** *មានន័យថាដាក់ក្នុងពន្ធនាគារសម្រាប់ការឃុំខ្លួនបណ្ដោះអាសន្នលើបទចោទប្រកាន់ជាក់លាក់ណាមួយ ឬដាក់ពន្ធនាគារបន្ទាប់ពីមានការកាត់ក្ដីឲ្យជាប់ទោស។*



# បរិបទក្នុងត្រីមាសនេះ

ត្រីមាសនេះដែលរាប់ចាប់ខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៣ ខេមបូចាកត់ត្រាករណីយាយីទៅលើអ្នកសារព័ត៌មានចំនួន៩ករណី និង ចំនួនអ្នកសារព័ត៌មានចំនួន១៤នាក់ (ក្នុងនោះស្ត្រីពីរនាក់)

# កាលបរិច្ឆេទនៃឧប្បត្តិហេតុដែល បានកើតឡើងក្នុងត្រីមាសនេះ

**២១ កញ្ញា** — **ក្រចេះ**

នគរបាលមូលដ្ឋានបានសាកសួរអ្នករៀបចំវគ្គបណ្តុះបណ្តាលអំពីក្រមសីលធម៌អ្នកសារព័ត៌មាន

**១៥ កញ្ញា** — **ភ្នំពេញ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គំរាមចាត់វិធានការផ្លូវច្បាប់លើខេមបូចា

**៣០ សីហា** — **ក្រចេះ**

ស្ថាប័នសារព័ត៌មានពីរត្រូវបានបង្ខំអោយលុបអត្ថបទចេញដែលសរសេរពីមន្ត្រីយោធាបំពុលបឹងនៅខេត្តក្រចេះ

**២២ សីហា** — **ភ្នំពេញ**

អ្នកសារព័ត៌មានវីអូអេត្រូវបានបណ្តេញចេញពី សន្និសីទសារព័ត៌មាននៅរដ្ឋសភា

**៩ សីហា** — **បាត់ដំបង**

អ្នកសារព័ត៌មានមកពីកាសែតកោះសន្តិភាពប្រឈមនៃការយាយីក្រោយធ្វើការរាយការណ៍ពីការបំពុលស្ទឹងសង្កែ

**២៣ កក្កដា** — **ភ្នំពេញ**

អ្នកសារព័ត៌មានត្រូវបានរឹតត្បិតពេលចុះយកព័ត៌មានក្នុងអំឡុងពេលបោះឆ្នោត២០២៣ អ្នកសារព័ត៌មានខ្លះត្រូវបានសួរនាំដោយមន្ត្រីរៀបចំការបោះឆ្នោតនៅពេលពួកគាត់សម្ភាសអនុប្រធានគណបក្សភ្លើងទាន

**១៤ កក្កដា** — **មណ្ឌលគិរី**

អ្នកសារព័ត៌មានបីនាក់មកពីស្ថាប័នសារព័ត៌មានខេមបូចាត្រូវបានសួរនាំពេលចុះយកព័ត៌មានពីដីសម្បទានសង្គមកិច្ចដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច

**១២ កក្កដា** — **ភ្នំពេញ**

រដ្ឋាភិបាលបង្កើនការពិនិត្យខ្ទឹមសារលើគេហទំព័រព័ត៌មានរិះគន់ មុនការបោះឆ្នោតជាតិមកដល់

# ឧប្បត្តិហេតុរាយការណ៍ក្នុងត្រីមាសនេះ

## ១. នគរបាលមូលដ្ឋានបានសាកសួរអ្នករៀបចំវគ្គបណ្ដុះបណ្ដាលអំពីក្រមសីលធម៌អ្នកសារព័ត៌មាន

**ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ ខេត្តក្រចេះ**

នគរបាលមូលដ្ឋាន ក្នុងខេត្តក្រចេះ បានសាកសួរអ្នករៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីក្រមសីលធម៌អ្នកសារព័ត៌មានរបស់ខេមបូចា។ មន្ត្រីនគរបាលពីរនាក់បានស្នើសុំមើលរបៀបវារៈនៃវគ្គបណ្ដុះបណ្ដាល ថតរូបវគ្គបណ្ដុះបណ្ដាល និង សុំបញ្ជីឈ្មោះអ្នកចូលរួម។

នគរបាលក៏បានសួររកឈ្មោះគ្រូឧទ្ទេសនាម ចំនួនអ្នកចូលរួម ថាតើសិក្ខាកាមមកពីណា និង វគ្គបណ្ដុះបណ្ដាលមានគោលបំណងអ្វី។

នគរបាលបាននិយាយថាវាជានីតិវិធីធម្មតាក្នុងខេត្តដែលត្រូវដឹងពីការជួបជុំការប្រជុំនិងសិក្ខាសាលាទាំងអស់ដែលធ្វើឡើងដោយគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល និង សមាគមនានា។

ទោះយ៉ាងណាក្ដី អ្នករៀបចំកម្មវិធីបានបដិសេធមិនផ្ដល់បញ្ជីឈ្មោះអ្នកចូលរួមទេ ប៉ុន្តែបានយល់ព្រមផ្ដល់ឱ្យនគរបាល នូវរបៀបវារៈនៃវគ្គបណ្ដុះបណ្ដាល និង រូបភាពនៃវគ្គបណ្ដុះបណ្ដាល។

មន្ត្រីនគរបាលម្នាក់ក្នុងសម្លៀកបំពាក់ស៊ីវិលដែលកំពុងសរសេរកំណត់ត្រាបាននិយាយថា៖ «នេះជាបញ្ជាពីលោកស្នងការនគរបាលខេត្ត។

នគរបាលបានចាកចេញពីកន្លែងវគ្គបណ្ដុះបណ្ដាលបន្ទាប់ពីសាកសួររួច។

ទោះជាយ៉ាងនេះក្ដី ដោយសាររបៀបវារៈមាននិយាយឈ្មោះតំណាងមកពីអង្គការយូណេស្កូ ទើបមន្ត្រីនគរបាលត្រឡប់មកវិញម្ដងទៀត ដើម្បីសុំជួបតំណាងពីអង្គការយូណេស្កូ។

នគរបាលបានចាកចេញវិញ បន្ទាប់ពីមានការពន្យល់អំពីអវត្តមាននៃតំណាងអង្គការយូណេស្កូ។

ខេមបូចា កំពុងបើកវគ្គបណ្ដុះបណ្ដាលដល់អ្នកសារព័ត៌មានចំនួន៣០នាក់ (ស្រី៤នាក់) ដែលមកពីខេត្តក្រចេះ ព្រះវិហារ រតនគិរី ស្ទឹងត្រែង និង ខេត្តមណ្ឌលគិរី។ ដោយមានការបើកវគ្គបណ្ដុះបណ្ដាលរយៈពេលពីរថ្ងៃ ដោយរំពឹងថា អ្នកសារព័ត៌មាននឹងចេះសរសេរព័ត៌មានជាមូលដ្ឋាន និង យល់ដឹងពីក្រមសីលធម៌អ្នកសារព័ត៌មាន។



**ប្រភេទនៃការយាយី ៖** *ការបំភិតបំភ័យដោយពាក្យសម្តី*

**ប្រភព ៖** *សម្ភាសដោយ ខេមបូចា*

*វគ្គបណ្តុះបណ្តាលនេះ គឺជាផ្នែកមួយនៃគម្រោងរបស់ ខេមបូចា ក្នុងការផ្តល់ការកសាងសមត្ថភាពដល់អ្នកសារព័ត៌មានតាមតំបន់ដែលមានមូលដ្ឋាននៅក្នុងខេត្តក្រចេះ។ខេមបូចាទើបតែបញ្ចប់វគ្គបណ្តុះបណ្តាលដូចគ្នាសម្រាប់អ្នកសារព័ត៌មានចំនួន ២៨នាក់ នៅខេត្តសៀមរាប ពីថ្ងៃទី ៣០ ដល់ ៣១ ខែសីហា។ ពួកគេគឺជាបណ្តាញសាខាប្រចាំខេត្តបាត់ដំបង ៕*

## ២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គំរាមចាត់វិធានការផ្លូវច្បាប់ទៅលើ ខេមបូចា

**ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៣ រាជធានីភ្នំពេញ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្ញើលិខិតមួយច្បាប់ទៅកាន់និពន្ធនាយក ខេមបូចា។ នៅក្នុងលិខិតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានចោទ CamboJA News ថាបានរំលោភបំពានក្រមសីលធម៌អ្នកសារព័ត៌មាន ដោយសរសេរគ្មានភស្តុតាងសំអាង និង តាមការស្មាននៅក្នុងអត្ថបទដែលទើបចេញផ្សាយថ្មីៗនេះ។

លិខិតនេះត្រូវបានសរសេរជាការឆ្លើយតបទៅនឹងអត្ថបទមួយដែល ខេមបូចា បានចុះផ្សាយកាលពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០២៣។ អត្ថបទដែលមានចំណងជើងថា “គ្រួសារអ្នករិះគន់រដ្ឋាភិបាលដែលត្រូវគេវាយដំដោយហិង្សា ស្វែងរកយុត្តិធម៌” គឺនិយាយពីការវាយដំទៅលើអ្នករិះគន់គោលនយោបាយរដ្ឋាភិបាល និង ព្រឹត្តិការណ៍ក្រោយការវាយដំ។

លិខិតនោះបានស្នើឱ្យក្រុមសរសេរព័ត៌មានរបស់ខេមបូចា លុបចេញពីអត្ថបទនូវឈ្មោះរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក ឌិត ទីណា ក៏ដូចជាការដកចេញ “ការអះអាងគ្មានសមហេតុផល និង ការប៉ាន់ស្មាន”។ ក្រសួងអះអាងថា ការសរសេរទាំងនេះអាចប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង រដ្ឋមន្ត្រី ហើយថា អត្ថបទនេះត្រូវបានសរសេរ ដោយមានចេតនាដើម្បីបង្ខាញក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងន័យអវិជ្ជមាន។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គំរាមចាត់វិធានការផ្លូវច្បាប់ទៅលើ ខេមបូចា ប្រសិនបើសំណើនេះត្រូវបានបដិសេធ ឬប្រសិនបើ ខេមបូចា ធ្វើទង្វើដោយ "ចេតនាព្យាបាទ និងបង្ខូចកេរ្តិ៍ឈ្មោះ" ម្តងទៀត។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមានថា ខេមបូចា អាចទទួលបានលទ្ធផលដូចគ្នានឹងវីអូឌី ដែរ។

បន្ទាប់ពីបានពិភាក្សាជាមួយមេធាវី និងក្រុមសរសេរព័ត៌មានរួចមក ខេមបូចា បានសម្រេចចិត្តដកឈ្មោះ ឌិត ទីណា ចេញពីអត្ថបទ ក៏ដូចជាបានកែឈ្មោះប្រភព និងឈ្មោះការីនិពន្ធ ដើម្បីជៀសវាងចំណាត់ការផ្លូវច្បាប់ដែលនាំឱ្យមានការលុបអាជ្ញាបណ្ណ។

**ប្រភេទនៃការយោយី ៖** *ការគំរាមកំហែងផ្លូវច្បាប់*

**ប្រភព ៖**

១. *លិខិតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

២. https://tinyurl.com/2p9e9s7j

## ៣. អ្នកយកព័ត៌មាន VOA ត្រូវគេដេញចេញពីសន្និសីទកាសែតនៅរដ្ឋសភា

### ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ រាជធានីភ្នំពេញ

កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ រដ្ឋសភាកម្ពុជាបានធ្វើការ បោះឆ្នោតជ្រើសតាំងលោក ហ៊ុន ម៉ាណែត កូនប្រុសរបស់លោក ហ៊ុន សែន ដែលចេញពីតំណែង ឲ្យធ្វើជានាយករដ្ឋមន្ត្រីបន្ទាប់របស់ប្រទេសនេះ។

លោក លីប លីប អ្នកយកព័ត៌មានរបស់វីអូអេ (VOA) បានស្ថិតនៅក្នុងបន្ទប់សន្និសីទកាសែត ក្នុងរដ្ឋសភា ដើម្បីចូលយកព័ត៌មាន និងរាយការណ៍ព័ត៌មានអំពីការបោះឆ្នោតជ្រើសតាំង។ លោកបានចូលទៅក្នុងកន្លែងធ្វើសន្និសីទ មុននឹងសន្និសីទកាសែតចាប់ផ្តើម។

នៅម៉ោងប្រហែលម៉ោង ៨:១០ ព្រឹក លោក លីប លីប បាននិយាយថា ក៏ស្រាប់តែ មន្ត្រីរដ្ឋសភាបានបណ្តេញលោកចេញពីបន្ទប់សន្និសីទកាសែតនេះ។ ពួកគេមិនបានផ្តល់ហេតុផលទេ សូម្បីតែនៅពេលដែល លោក លីប លីប បានសួរពួកគេថាហេតុអ្វីបានជាពួកគេមិនអនុញ្ញាតឲ្យរូបលោកចូលរួមក្នុងសន្និសីទកាសែត។

លោក លីប លីប ត្រូវបានអនុញ្ញាតឱ្យឈរនៅក្នុងបន្ទប់សារព័ត៌មាន ប៉ុន្តែគេមិនអនុញ្ញាតឱ្យលោកចូលទៅកាន់កន្លែងធ្វើសន្និសីទដែលកំពុងប្រព្រឹត្តទៅនោះទេ។

អ្នកយកព័ត៌មាន និងអ្នកថតវីដេអូផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យចូលរួមសន្និសីទ។ លោក លីប លីប ជាអ្នកយកព័ត៌មានតែម្នាក់គត់នៅទីនោះ ដែលមកពីវិទ្យុវីអូអេ (VOA) ដែលគាំទ្រដោយសហរដ្ឋអាមេរិក។ លោកគឺជាអ្នកយកព័ត៌មានតែម្នាក់គត់ដែលត្រូវបានបង្ខំឱ្យចាកចេញពីកន្លែងធ្វើសន្និសីទកាសែត។

អ្នកយកព័ត៌មានវីអូអេ និងវីអូឌី ពីមុនត្រូវបានបដិសេធមិនឲ្យចូលរួមក្នុងសន្និសីទកាសែត ដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែវិច្ឆិកា ឆ្នាំ២០២២ បន្ទាប់ពីបញ្ចប់កិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា។

អ្នកនាំពាក្យក្រសួងព័ត៌មាន លោក មាស សោភ័ណ្ឌ បាននិយាយថា អ្នកយកព័ត៌មានមកពីអង្គភាពព័ត៌មានទាំងពីរ «មិនដែលចូលរួម» ក្នុងសន្និសីទកាសែតនោះទេ ហើយគេគ្រាន់តែ «កាត់យកតែពីរបីចំណុចប៉ុណ្ណោះ» ពីសុន្ទរកថាក្នុងសន្និសីទ ដើម្បីផ្សព្វផ្សាយ។

រូបភាពខាងក្រោមថតដោយលោក លីប លីប ជាអ្នកយកព័ត៌មានវីអូអេ មុនពេលគេបណ្តេញលោកចេញពីបន្ទប់ធ្វើសន្និសីទ៕



**ប្រភេទនៃការយាយី ៖** *ការបំភិតបំភ័យដោយពាក្យសម្ដី ការបំភិតបំភ័យផ្នែករាងកាយ*
**ប្រភព ៖** *សម្ភាសដោយ ខេមបូចា*

## ៤. អង្គភាពផ្សព្វផ្សាយចំនួនពីរត្រូវបានបង្ខំឱ្យលុបអត្ថបទដែលចោទមន្ត្រីយោធាម្នាក់ថាបានបំពុលបឹងសាធារណៈ

**ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ខេត្តក្រចេះ**

*អ្នកសារព័ត៌មានអនឡាញ ពីរនាក់មកពីអង្គភាពព័ត៌មានអនឡាញ RSE-News និង Newnetwork ប្រចាំខេត្តរតនគិរី ត្រូវបានអាជ្ញាធរខេត្តក្រចេះ ប្តឹងពីបទញុះញង់ និង បរិហារកេរ្តិ៍។ រឿងនេះបានកើតឡើងបន្ទាប់ពីអ្នកសារព័ត៌មានបានរាយការណ៍ព័ត៌មានម្តងហើយម្តងទៀតអំពីការចាក់ដីលុបផ្នែកខ្លះនៃបឹងសាធារណៈក្នុងស្រុកស្នួល ខេត្តក្រចេះ។*

*លោក សុង គឹមហេង នាយកសារព័ត៌មាន រាជសីហ៍ភ្លៀសាន និង លោក ជី មូ នាយកសារព័ត៌មាន* Newnetwork-news *បានបញ្ជាក់ថា ពួកគេបានទទួលលិខិតកោះហៅពីមេប៉ុស្តិ៍នគរបាលឃុំ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៣។ លិខិតនេះត្រូវបានចេញដោយតុលាការខេត្តក្រចេះ និង មានដីកាកោះឲ្យចូលខ្លួនទៅតុលាការនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣។*

*ទាំងសារព័ត៌មាន* RSE News *និង* Newnetwork *បានរាយការណ៍ព័ត៌មានម្តងហើយម្តងទៀតថា លោក យ៉ាន់ សុវណ្ណ ដែលគេស្គាល់ថាជាមន្ត្រីយោធាម្នាក់នៅស្រុកស្នួល បានបំពុលបឹងសាធារណៈដោយចាក់ដីលុបដើម្បីអភិវឌ្ឍរមណីយដ្ឋាន និងក្លឹប ខេធីវី* (KTV) *។ បឹងនេះត្រូវបានគេដឹងថា កសាងឡើងក្នុងរបបប៉ុលពត ហើយគេច្រើនតែប្រើប្រាស់ស្រះទឹកនេះ ដើម្បីបម្រើផលប្រយោជន៍ដល់ជនជាតិដើមភាគតិចនៅតំបន់នេះ។*

*លោក សុង គឹមហេង បាននិយាយថា លោកបានរាយការណ៍អំពីករណីចាក់ដីលុបបឹងនេះ កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ដោយបានសម្ភាសអ្នកពាក់ព័ន្ធ។ លោកថា ក្រោយចេញផ្សាយព័ត៌មាន ស្រាប់តែលោកអភិបាលខេត្តបានណែនាំឲ្យមន្ទីរធនធានទឹក និងឧតុនិយមខេត្តក្រចេះស៊ើបអង្កេតករណីនេះប៉ុន្តែនៅតែមិនអាចដោះស្រាយបានទេ។*

*លោក គឹមហេង បាននិយាយថា លោកបន្តរាយការណ៍ព័ត៌មានអំពីករណីនេះរហូតដល់ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៣។ ពីរសប្តាហ៍ក្រោយមក លោកបានទទួលដីកាកោះហៅពីតុលាការខេត្តក្រចេះ ឱ្យចូលខ្លួនទៅតុលាការនៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០២៣។*

*លោកគឹមហេងបានឲ្យដឹងថាលោកយ៉ាន់សុវណ្ណបានស្នើឲ្យខ្លួនដកអត្ថបទចេញបើមិនដូច្នេះទេត្រូវប្រឈមនឹងវិធានការផ្លូវច្បាប់។ លោក គឹមហេង បានបន្តថា ពាក្យបណ្តឹងត្រូវបានដកចេញពីតុលាការ បន្ទាប់ពីពួកគេបានយល់ព្រមដកអត្ថបទនោះចេញ។*

**ប្រភេទនៃការយាយី ៖** *ការគំរាមកំហែងផ្លូវច្បាប់*

**ប្រភព ៖** *សម្ភាសដោយ ខេមបូចា*

## ៥. ភ្នាក់ងារសារព័ត៌មានកោះសន្តិភាព ប្រចាំខេត្តបាត់ដំបង ប្រឈមនឹងការយាយី ខណៈរាយការណ៍ពីការបំពុលទឹកស្ទឹងសង្កែ

**ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ខេត្តបាត់ដំបង**

*លោក ឆោម ពិសម័យ អាយុ ៥២ឆ្នាំ ភ្នាក់ងារសារព័ត៌មានរបស់កាសែតកោះសន្តិភាព ប្រចាំខេត្តបាត់ដំបង ទទួលរងការយាយីពីសំណាក់អាជ្ញាធរខេត្តបាត់ដំបង ដែលគំរាមប្ដឹងគាត់ បន្ទាប់ពីគាត់បានរាយការណ៍ព័ត៌មានម្ដងហើយម្ដងទៀត ទាក់ទងនឹងរោងចក្រចិននៅស្ទឹងសង្កែ ដែលបង្កឲ្យមានការបំពុលទឹកក្នុងតំបន់ជុំវិញនោះ។*

*លោក ពិសម័យ បាននិយាយថា កាលពីថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ មន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានទូរស័ព្ទមកប្រាប់លោកថា អភិបាលខេត្តបាត់ដំបង គឺលោក សុខ លូ បានបញ្ជាឱ្យសមត្ថកិច្ចស៊ើបអង្កេតសាវតារបស់លោក។ ពួកគេបាននិយាយថា គេធ្វើបែបនេះ ដើម្បីរៀបចំដាក់ពាក្យបណ្ដឹងញុះញង់ទាក់ទងនឹង ការរាយការណ៍ព័ត៌មានរបស់គាត់ អំពីការបំពុលស្ទឹងសង្កែដោយ រោងចក្រចិន។ មន្ត្រីនគរបាលបាននិយាយថា វាប៉ះពាល់ដល់សមត្ថកិច្ច។ លោក ពិសម័យ បានរាយការណ៍ព័ត៌មានជាបន្តបន្ទាប់ ទាំងបង្ហោះនៅលើគេហទំព័រព័ត៌មានកោះសន្តិភាព ទាំងនៅលើទំព័រហ្វេសប៊ុកផ្ទាល់ខ្លួនរបស់លោក ដោយរិះគន់អាជ្ញាធរថាមិនបានដោះស្រាយការបំពុលទឹកស្ទឹង។*

*កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣ ក្រសួងបរិស្ថានបានបង្ហាញភស្តុតាងថា រោងចក្រចិនឈ្មោះ* Phoenix Industry Co,Ltd *ដែលមានទីតាំងនៅក្នុងភូមិផ្សារ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ពិតជាបានបង្កការបំពុលទឹកនៅក្នុងស្ទឹងសង្កែមែន។ បន្ទាប់ពីប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍អំពីបញ្ហានេះ ពួកគេបានបង្ហាញពីការបាត់បង់ជីវៈចម្រុះនៃទឹកស្ទឹងក៏ដូចជាការពិតដែលវាបានធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជនជាច្រើន។ ក្រសួងបានផាកពិន័យរោងចក្រជាទឹកប្រាក់ចំនួន ៤០ ម៉ឺនដុល្លារ និងបញ្ជាឲ្យរោងចក្រនេះរុះរើចេញយ៉ាងតិច ១០ គីឡូម៉ែត្រពីមាត់ស្ទឹងសង្កែ។*

**ប្រភេទនៃការយាយី ៖** *ការបំភិតបំភ័យដោយពាក្យសម្ដី និង ការគំរាមកំហែងផ្លូវច្បាប់*

**ប្រភព ៖** ១. *សម្ភាសដោយ ខេមបូចា*

២. https://tinyurl.com/5h5j6s4y

៣. https://tinyurl.com/yv84mdhe

## ៦. អ្នកសារព័ត៌មានត្រូវដាក់កំហិតក្នុងការយកព័ត៌មានក្នុងអំឡុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ ២០២៣

**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ រាជធានីភ្នំពេញ**

ក្នុងអំឡុងពេលបោះឆ្នោត អ្នកសារព័ត៌មានយ៉ាងហោចណាស់១០នាក់បានប្រឈមនឹងការរឹតត្បិតពេលចុះយកព័ត៌មាន។ មន្ត្រីការិយាល័យបោះឆ្នោតបាននិយាយតតាំងនឹងអ្នកសារព័ត៌មាន ជារឿយៗដោយរារាំងពួកគេមិនឱ្យថតរូប និង សម្ភាសនៅខាងក្នុងបរិវេណការិយាល័យបោះឆ្នោត។ អ្នកសារព័ត៌មានខ្លះត្រូវបានអនុញ្ញាតឱ្យបន្តធ្វើការ បន្ទាប់ពីមិនព្រមធ្វើតាម ប៉ុន្តែអ្នកសារព័ត៌មាន ភាគច្រើននៅតែត្រូវបានរារាំងមិនឲ្យចូលទៅក្នុងការិយាល័យបោះឆ្នោតទាំងស្រុង។ ក្នុងករណីខ្លះ មន្ត្រីបោះឆ្នោតថែមទាំងថតរូបអ្នកសារព័ត៌មានដើម្បីធ្វើរបាយការណ៍ដែរ។

នៅម៉ោងប្រមាណ៩ព្រឹក ព្រះអង្គម្ចាស់នរោត្តម ចក្រាវុធ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច បានយាងទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតវត្តវាលស្បូវ សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ។ អ្នកថតរូប និង អ្នកថតវីដេអូមួយក្រុម ត្រូវបានហាមប្រាមមិនឲ្យចូលក្នុងបន្ទប់បោះឆ្នោត ដើម្បីថតរូបព្រះអង្គ ពេលព្រះអង្គទៅបោះឆ្នោតទេ ទោះបីជាពួកគេកាន់បណ្ណព័ត៌មានដែលចេញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ដោយ។

អ្នកថតរូបម្នាក់ដែលសុំមិនបញ្ចេញឈ្មោះបានប្រាប់ ខេមបូចា ថា អ្នកថតរូបតម្រូវឱ្យឈរនៅខាងក្រៅខ្លោងដែលពិបាកថតរូប។ លោកថា គេបានប្រាប់អ្នកថតរូបឲ្យឈរឆ្ងាយពីបន្ទប់បោះឆ្នោតដើម្បីថតរូប។ លោកបានបន្តថា "ខ្ញុំបានប្រាប់ [មន្ត្រី គ.ជ.ប] ថា យើងអាចថតរូបលោក ហ៊ុន សែន និង លោកហ៊ុន ម៉ាណែត ហើយចុះហេតុអ្វីយើងមិនអាចថតរូបបាននៅទីនេះ? លោកថា៖ «ខ្ញុំមានបណ្ណកាសែតដែលចេញដោយ គ.ជ.ប ចុះហេតុអ្វីខ្ញុំមិនអាចចូលទៅថតរូបបាន?

លោក អ៊ួន ឈិន ដែលជាផលិតករវីដេអូរបស់ ខេមបូចា បាននិយាយថា នៅវេលាម៉ោង ១១ និង ២៥ នាទីព្រឹក លោកក៏ឈរនៅការិយាល័យបោះឆ្នោតវាលស្បូវដែរ។ ពេលកំពុងថតវីដេអូ អង្គរក្សរបស់ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ព្រះអង្គម្ចាស់ ចក្រាវុធ បានគំរាមយកទូរស័ព្ទរបស់លោកបោះចោលម្តងហើយម្តងទៀត ដោយចោទលោកថា បានចូលកៀក និងប៉ះព្រះកាយព្រះអង្គម្ចាស់ ខណៈកំពុងថតរូបព្រះអង្គ។

លោក ឈិន បានដកស្រង់សំដីគំរាមរបស់អង្គរក្សនោះថា៖ «ខ្ញុំនឹងបោកទូរស័ព្ទរបស់លោកចោល ប្រសិនបើលោកថតប៉ះព្រះអង្គ [ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ] ម្តងទៀត»។

ភ្លាមៗនោះ លោក ឈិន ក៏បានបដិសេធថាលោកមិនបានប៉ះព្រះអង្គទេ។ លោកបានឆ្លើយតបវិញថា "ទេ ខ្ញុំមិនបានប៉ះនរណាទេ"។ បន្ទាប់មកអង្គរក្សនោះបាននិយាយថា "បីដងហើយ!"

*លោក ស៊ិន ណារិន អ្នកយកព័ត៌មានរបស់វីអូអេ (VOA) បាននិយាយថា លោកត្រូវបានមន្ត្រីរៀបចំការបោះឆ្នោតហាមមិនឲ្យថតរូបនិងសម្ភាសប្រជាពលរដ្ឋនៅការិយាល័យបោះឆ្នោត។ លោកណារិនបានថ្លែងថា នៅការិយាល័យបោះឆ្នោតផ្សារថ្មី២ មន្ត្រី គ.ជ.ប ហាមលោកមិនឲ្យថតរូបទេ ប៉ុន្តែបន្ទាប់ពីលោកជជែកតវ៉ានឹងគាត់លោកក៏ត្រូវបានអនុញ្ញាតឱ្យថតរូបប៉ុន្តែមិនឱ្យសម្ភាសអ្នកបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតទេ។*

*លោកថា លោកបានបង្ហាញកាតកាសែតដែលចេញដោយ គ.ជ.បដល់មន្ត្រីទាំងនោះ។ លោកបាននិយាយថា "យើងមិនបានចូលទៅក្នុងបន្ទប់ដើម្បីថតរូបទេ។ យើងបានឈរនៅខាងក្រៅ ប៉ុន្តែគេមិនអនុញ្ញាតទៀត។ ការិយាល័យដែលខ្ញុំទៅយកព័ត៌មានគឺលើផ្លូវ ហើយគេមិនអនុញ្ញាតឲ្យខ្ញុំសម្ភាសអ្នកបោះឆ្នោតនៅទីនោះទេ»។*

*ដូចគ្នានេះដែរ ការីនិពន្ធ ខេមបូចា អ្នកនាង Leila Goldstein ត្រូវបានបុគ្គលិករៀបចំការបោះឆ្នោតហាមមិនឲ្យថតរូបនៅក្នុងការិយាល័យបោះឆ្នោតបឋមសិក្សាទួលស្វែងក្នុងសង្កាត់ទួលស្វាយព្រៃទី១រាជធានីភ្នំពេញទេ។*

*អ្នកនាងបាននិយាយថា៖«ខ្ញុំត្រូវបានបុគ្គលិករៀបចំការបោះឆ្នោតនៅបន្ទប់ពីរផ្សេងគ្នាបាប្រ់ថា គេមិនអនុញ្ញាតឱ្យខ្ញុំនៅក្នុងបន្ទប់ ឬថតរូបនោះទេ»។*

*អ្នកនាង Leila បាននិយាយថា បុគ្គលិករៀបចំការបោះឆ្នោតបានសុំឱ្យអ្នកនាងចាកចេញពីការិយាល័យបោះឆ្នោត ប៉ុន្តែនាងមិនព្រមធ្វើតាមទេ។*

*អ្នកនាងបានបន្តថា៖ «ខ្ញុំមិនព្រមចេញទេ ហើយបន្ទាប់មកពួកគេបានដើរចេញទៅ ហើយក៏ជជែកជាមួយអ្នកគ្រប់គ្រងរួចមក ទើបឈប់មករំខានខ្ញុំ»៕*

**ប្រភេទនៃការយាយី ៖** *ការបំភិតបំភ័យដោយពាក្យសម្តី ការបំភិតបំភ័យផ្នែករាងកាយ*
**ប្រភព ៖** *សម្ភាសដោយ ខេមបូចា*

## ៧. អ្នកយកព័ត៌មានត្រូវបានចោទសួរដោយមន្ត្រីរៀបចំការបោះឆ្នោត ពេលកំពុងសម្ភាសអនុប្រធានគណបក្សភ្លើងទៀន

**ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ ខេត្តកណ្ដាល**

*អ្នកសារព័ត៌មានបីនាក់របស់វីអូអេ និង ខេមបូចា ត្រូវបានប្រធានការិយាល័យបោះឆ្នោតមួយក្នុងខេត្តកណ្ដាលសាកសួរ ខណៈពួកគេកំពុងសម្ភាសអនុប្រធានគណបក្សភ្លើងទៀន លោក រ៉ុង ឈុន។*

*កញ្ញា សុវណ្ណ ស្រីពេជ្រ អ្នកយកព័ត៌មានខេមបូចា បាននិយាយថា នាង និង អ្នកយកព័ត៌មានពីរនាក់ទៀតរបស់វីអូអេ បានទៅយកព័ត៌មាននៅការិយាល័យបោះឆ្នោតនៅអនុវិទ្យាល័យតាឡូន ស្រុកស្អាង ខេត្តកណ្ដាល ដែលអនុប្រធានគណបក្សភ្លើងទៀន គឺលោក រ៉ុង ឈុន បានទៅបោះឆ្នោត។*

*កញ្ញាបានបន្តថា ពេលកំពុងសម្ភាស ស្រាប់តែនគរបាល បានមកសួរប្រធានការិយាល័យបោះឆ្នោតអំពីអ្នកសារព័ត៌មានដែលមានវត្តមាននៅការិយាល័យបោះឆ្នោត។*

*កញ្ញាបានបន្តថា បន្ទាប់មក ប្រធានការិយាល័យបោះឆ្នោតបានដើរសំដៅមកអ្នកសារព័ត៌មាន ហើយសួរថាអ្នកសារព័ត៌មានមកពីណា។ ក្រោយពីសាកសួររួច ប្រធានការិយាល័យបោះឆ្នោតរូបនោះបានថតរូបនាង និង អ្នកសារព័ត៌មានផ្សេងទៀតមកធ្វើរបាយការណ៍។*

*លោក លីប លីប អ្នកយកព័ត៌មានរបស់វីអូអេ បាននិយាយថា លោកក៏បានទៅការិយាល័យបោះឆ្នោតនៅអនុវិទ្យាល័យតាឡូនដែរ។ លោកថា អ្នកយកព័ត៌មានបានសុំការអនុញ្ញាតពីប្រធានការិយាល័យបោះឆ្នោតដើម្បីថតរូប និងសម្ភាសក្នុងការិយាល័យបោះឆ្នោត។*

*លោកថា ពេលកំពុងសម្ភាស ប្រធានការិយាល័យបោះឆ្នោតក៏បានថតរូបអ្នកយកព័ត៌មានដែរ៕*

**ប្រភេទនៃការយាយី ៖** *ការបំភិតបំភ័យដោយពាក្យសម្ដី*
**ប្រភព ៖** *សម្ភាសដោយ ខេមបូចា*

## ៨. អ្នកយកព័ត៌មានបីនាក់ពីខេមបូចាត្រូវបានអាជ្ញាធរសួរនាំ ពេលចុះយកព័ត៌មាន នៅខេត្តមណ្ឌលគិរី

**ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ខេត្តមណ្ឌលគិរី**

*នៅម៉ោងប្រហែល១០ព្រឹក អាជ្ញាធរចម្រុះមកពីស្រុកកោះញែក ខេត្តមណ្ឌលគិរី បានសាកសួរអ្នកយកព័ត៌មានខេមបូចា ដែលចុះយកព័ត៌មានអំពីសម្បទានដីសង្គមកិច្ច ដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច។ អាជ្ញាធរគ្រោងកាត់ដីស្រុកកោះញែកចំនួន៦.០០០ហិកតានៅភូមិយោលលើដែលប៉ះពាល់ដល់ជនជាតិដើមភាគតិចរស់នៅទីនោះ។*

*អាជ្ញាធរបានសួរអ្នកសារព័ត៌មានថា «ហេតុអ្វីបានជាអ្នកមកទីនេះ? ហេតុអ្វីបានជាអ្នកមកទីនេះចំថ្ងៃដែលអាជ្ញាធរចុះមកដែរ? អ្នកណាប្រាប់? តើអ្នកមកពីស្ថាប័នណា?"*

*បុរសម្នាក់ត្រូវបានគេស្គាល់ថាជាមន្ត្រីសាលាស្រុកកោះញែកបានដើរសំដៅទៅរកអ្នកសារព័ត៌មាន ហើយបានស្រែកគំហកខ្លាំងៗថា "ម៉េចបានជាជនបរទេសមកនៅក្នុងព្រៃ?" ម៉េចមិនប្រាប់អាជ្ញាធរជាមុន? មន្ត្រីរូបនោះបានបន្តថា "បើមានបញ្ហា តើនរណាជាអ្នកទទួលខុសត្រូវ? "*

*បន្ទាប់មកអាជ្ញាធរបានថតរូបអ្នកយកព័ត៌មាន។ មន្ត្រីម្នាក់ទៀតបានមកសួរថា"ម៉េចបានជាអ្នក[អ្នកកាសែត] មកទីនេះដោយគ្មានការអញ្ជើញអ៊ីចឹង? ហើយអ្នកណាជាអ្នកផ្តល់ព័ត៌មាន?"*

*ជនជាតិដើមភាគតិចប្រារព្ធពិធីសាសនារបស់ពួកគេដើម្បីបួងសួងកុំឱ្យអាជ្ញាធរដកហូតដីព្រៃសហគមន៍របស់ពួកគេ ហើយអ្នកយកព័ត៌មានរបស់ខេមបូចា បានចុះមកយកព័ត៌មាននេះ។*

*អាជ្ញាធរបាននិយាយថា «កម្មវិធីនេះសម្រាប់សហគមន៍ និងក្រសួងទេ ហេតុអ្វីបានជាអ្នកសារព័ត៌មានមកដែរ?»។*

*អ្នកសារព័ត៌មានបានឆ្លើយថា «ពួកយើងសរសេររឿងនេះ ដោយមិនមានភាពចម្រូងចម្រាស់ទេ គ្រាន់តែនិយាយពីការពិតនៃអ្វីដែលបានកើតឡើងប៉ុណ្ណោះ យើងមកសរសេរបន្ត និងរាយការណ៍ព័ត៌មាន»។*

**ប្រភេទនៃការឃោរឃៅ ៖** *ការគំរាមកំហែងដោយពាក្យសម្តី*
**ប្រភព ៖** *សម្ភាសដោយ ខេមបូចា*

## ៩. រដ្ឋាភិបាលបង្កើនការពិនិត្យខ្លឹមសារលើគេហទំព័រព័ត៌មានរិះគន់ មុនការបោះឆ្នោតជាតិមកដល់

**ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣ រាជធានីភ្នំពេញ**

*ក្រសួងព័ត៌មានបាន បញ្ជាឲ្យ និយតករទូរគមនាគមន៍កម្ពុជា (TRC) បិទគេហទំព័រ និង ទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ប្រព័ន្ធផ្សព្វផ្សាយមួយចំនួន និងគេហទំព័រកំណត់ត្រារបស់ CCIM។*

*បទបញ្ជានេះ បញ្ជាក់ថា ការពិនិត្យចាប់កំហុសគឺដោយសារតែការផ្សាយព័ត៌មានដែលរិះគន់រដ្ឋាភិបាល ដោយអះអាងថា ប្រព័ន្ធផ្សព្វផ្សាយ និង ទិន្នន័យផ្សព្វផ្សាយព័ត៌មានដែល «ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងកិត្យានុភាពរបស់រដ្ឋាភិបាល»។*

*ការបិទគេហទំព័រទាំងនេះបានរឹតត្បិតការចូលប្រើគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមដែលពាក់ព័ន្ធជាមួយ ខេមបូឌា ដេលី និង វិទ្យុអាស៊ីសេរី និងគេហទំព័រកំណត់ត្រា ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។*

*មុនពេលឈានដល់ការបោះឆ្នោតជាតិដែលប្រព្រឹត្តទៅនៅ ថ្ងៃអាទិត្យ ទី២៣ ខែកក្កដា ឆ្នាំ២០២៣ រដ្ឋាភិបាលបានបំបិទសិទ្ធិពលរដ្ឋកម្ពុជា ជាពិសេសសិទ្ធិទទួលបានព័ត៌មាន៕*

**ប្រភេទនៃការឃោរឃៅ ៖** *ការបំភិតបំភ័យតាមប្រព័ន្ធបច្ចេកវិទ្យា*

**ប្រភព ៖** https://tinyurl.com/yc73e8kc

# បច្ចុប្បន្នភាពសំខាន់ៗ

## ១. រដ្ឋាភិបាលបង្កើតគណៈកម្មាធិការសម្របសម្រួលព័ត៌មាន និង សាធារណមតិ និង លើកកម្ពស់រូបភាពវិជ្ជមាននៃប្រទេសកម្ពុជា

*រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការមួយ ដើម្បីពង្រឹងសាធារណមតិ និង តាមដានព័ត៌មានក្នុងប្រទេស ហើយអ្នកតស៊ូមតិបារម្ភថា ស្ថាប័នរដ្ឋាភិបាលនឹងរាំងសេរីភាពនៃការបញ្ចេញមតិ និង សារព័ត៌មាន។*

*អនុក្រឹត្យថ្មីនេះដែលត្រូវបានផ្សព្វផ្សាយជាសាធារណៈកាលពីថ្ងៃអង្គារ គឺបានបង្កើតគណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការព័ត៌មាន និងសាធារណមតិ។ គណៈកម្មាធិការនេះមានភារកិច្ច “ពិនិត្យ និង តាមដាន” គ្រប់ស្ថានភាពទាំងអស់ ព្រមទាំងពន្យល់ និងការពារ “រូបភាពវិជ្ជមាននៃព្រះរាជាណាចក្រកម្ពុជា”។ ការទទួលខុសត្រូវបន្ថែមរួមមានការលើកកម្ពស់ “កិត្យានុភាព” របស់កម្ពុជានៅក្នុង និងក្រៅប្រទេស ការផ្សព្វផ្សាយសមិទ្ធិផលរបស់ប្រទេស ការពារអធិបតេយ្យភាពជាតិ និង សហការជាមួយប្រព័ន្ធផ្សព្វផ្សាយ ដើម្បីចែករំលែកខ្លឹមសារ។*

*អនុក្រឹត្យនេះកំណត់យ៉ាងច្បាស់ថាស្ថាប័នរដ្ឋាភិបាលនឹងបង្កើតយន្តការមួយដើម្បីឆ្លើយតបទៅនឹង"ព័ត៌មានមិនពិត" ឲ្យកាន់តែមានប្រសិទ្ធភាព។*

*ការបង្កើតគណៈកម្មាធិការនេះ បានធ្វើឲ្យសកម្មជនមួយចំនួនព្រួយបារម្ភថា នឹងបង្កើនការត្រួតពិនិត្យព័ត៌មានដែលនាំឲ្យមានបញ្ហាទាក់ទងនឹងសេរីភាពសារព័ត៌មាន និង សេរីភាពនៃការបញ្ចេញមតិ។*

**ប្រភព ៖** https://tinyurl.com/2s9wtw8w

## ២. អ្នកសារព័ត៌មានត្រូវបានដោះលែង បន្ទាប់ពីជាប់ពន្ធនាគារ ២ឆ្នាំ

*លោក កៅ ពិសិដ្ឋ អ្នកសារព័ត៌មានអនឡាញប្រចាំខេត្តបាត់ដំបង ត្រូវបានដោះលែងនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ បន្ទាប់ពីជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ។*

*អ្នកសារព័ត៌មានរូបនេះត្រូវបានចាប់ខ្លួន បន្ទាប់ពីរិះគន់ជាសាធារណៈចំពោះការប្រើប្រាស់វ៉ាក់សាំងរបស់រដ្ឋាភិបាល ដែលផលិតដោយប្រទេសចិន។*

*ការចាប់ខ្លួននេះបាននាំឲ្យចំនួនអ្នកសារព័ត៌មាន ដែលត្រូវបានចាប់ខ្លួននៅឆ្នាំ ២០២១កើនឡើងដល់៤នាក់ ដោយសារការរាយការណ៍ព័ត៌មានរបស់ពួកគេអំពីការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះជំងឺរាតត្បាត។*

*លោកពិសិដ្ឋដែលធ្វើជាអ្នកកសារព័ត៌មានជាង៨ឆ្នាំត្រូវបានចាប់ខ្លួននិងចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ នៅឆ្នាំ២០២១។*

*លោក ពិសិដ្ឋ បានប្រាប់ខេមបូចា កាលពីថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២៣ ថា ការចោទប្រកាន់មកលើរូបលោក គឺអយុត្តិធម៌។*

*លោកថា៖ «គ្មានចំណុចណាមួយដែលត្រូវចោទប្រកាន់ខ្ញុំពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ព្រោះគ្មាននរណាម្នាក់បានធ្វើតាមខ្ញុំនោះទេ»។*

*លោក ពិសិដ្ឋ និយាយថា លោកនៅតែបន្តធ្វើការជាអ្នកសារព័ត៌មាន ហើយបន្តរាយការណ៍ព័ត៌មានអំពីបញ្ហារសើបៗដែលប្រព័ន្ធផ្សព្វផ្សាយដទៃមិនអាចធ្វើបាន។*

*លោកថា "ខ្ញុំនៅតែធ្វើការជាអ្នកសារព័ត៌មាន។ ឥឡូវ ខ្ញុំបានដាក់ពាក្យសុំកាតសារព័ត៌មាន ពីក្រសួងព័ត៌មាន ប៉ុន្តែខ្ញុំមិនច្បាស់ថា ខ្ញុំនឹងទទួលបានកាតឬអត់នោះទេ»។*

*លោក ពិសិដ្ឋបានបម្រើការឱ្យអង្គភាពសារព័ត៌មានជាច្រើន ដូចជាទីភ្នាក់ងារព័ត៌មានប្រចាំខេត្តសៀមរាប និងព័ត៌មានផ្សព្វផ្សាយសង្គមជាតិ។*

**ប្រភព ៖** https://tinyurl.com/be47jyy7

# ករណីសិក្សា ៖ រដ្ឋាភិបាលបានបញ្ជាឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិត (ISPs) បិទគេហទំព័រកំណត់ត្រាកាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៣

រដ្ឋាភិបាលកម្ពុជាបានចេញបញ្ជាឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិត (ISP) បិទគេហទំព័រ និងទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ប្រព័ន្ធផ្សព្វផ្សាយល្បីៗបីនៅក្នុងប្រទេស។

គេហទំព័រដែលរងផលប៉ះពាល់ មានដូចជា ខេមបូឌាដេលី វិទ្យុអាស៊ីសេរី និង ទំព័រទិន្នន័យសាធារណៈដែលទើបបើកថ្មី គឺគេហទំព័រកំណត់ត្រា ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលកម្ពុជាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM)។

បទបញ្ជានេះបាននាំឱ្យមានការរឹតត្បិតបន្ថែមទៀតទៅលើគេហទំព័រអនឡាញនៅកម្ពុជា ដែលប៉ះពាល់ដល់សិទ្ធិទទួលបានព័ត៌មានរបស់អ្នកបោះឆ្នោតពីប្រភពផ្សេងៗគ្នាខណៈដែលកម្ពុជាកំពុងប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យ។

ការរឹតត្បិតតាមអនឡាញ បានក្លាយជាបញ្ហាប្រឈមសម្រាប់សេរីភាព និង សុវត្ថិភាពអ្នកសារព័ត៌មាននៅកម្ពុជា។ អ្នកសារព័ត៌មានប្រឈមមុខនឹងការយាយី ហើយប្រព័ន្ធផ្សព្វផ្សាយត្រូវទទួលរងចំណាត់ការរបស់រដ្ឋាភិបាលដែលនាំឱ្យមានការរឹតត្បិតលើខ្លួនឯង ដោយសារតែខ្លាចរអានឹងការសងសឹក។

ការរឹតត្បិតសមត្ថភាពរបស់អ្នកសារព័ត៌មានក្នុងការរាយការណ៍ព័ត៌មានដោយសេរីនិងរាំងសមត្ថភាពរបស់ពួកគេក្នុងការផ្តល់ព័ត៌មានដែលមិនលំអៀងឱ្យសាធារណជន។

លោក ណុប វី នាយកប្រតិបត្តិខេមបូចា បាននិយាយថា "ការបិទមិនឲ្យចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យតាមអ៊ីនធឺណិត ដែលកំពុងផលិតព័ត៌មានរិះគន់ គឺបានប៉ះពាល់ដល់សេរីភាពសារព័ត៌មាន និង ការទទួលបានព័ត៌មានរបស់ប្រជាជនកម្ពុជា"។

លោកថា៖ "ប្រជាជនគួរតែទទួលបានការធានា ការចូលប្រើប្រាស់មាតិកាចម្រុះ អ៊ីចឹងទើបពួកគេអាចធានាសិទ្ធិរបស់ពួកគេបានត្រឹមត្រូវ។ ការដាក់កំហិតលើមានតិកានេះបានបង្កើតផលប៉ះពាល់ដល់សេរីភាពសារព័ត៌មានជាប្រព័ន្ធផ្សព្វផ្សាយចម្រុះ ដែលគួរតែជាការធានាផងដែរ។

ចាប់តាំងពីមុនការបោះឆ្នោតជាតិឆ្នាំ ២០១៨ មក ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយអនឡាញរបស់កម្ពុជាបានផ្លាស់ប្តូរយ៉ាងខ្លាំង។ ក្នុងឆ្នាំ ២០១៧ សង្គមស៊ីវិលត្រូវបានលើកស្ទួយដោយមានស្ថាប័នព័ត៌មានឯករាជ្យមួយចំនួន។ ទោះជាយ៉ាងណាក្តី រយៈពេលពីឆ្នាំ ២០១៧ដល់២០២៣ អង្គភាពសារព័ត៌មានទាំងនោះ ដែលប្រឈមមុខ

នឹងការបិទដោយបង្ខំ និង ការរឹតត្បឹត របស់រដ្ឋាភិបាល គឺកាន់តែមានចំនួនតិចទៅៗ រហូតនៅសល់តែពីរបីអង្គភាពប៉ុណ្ណោះ។

ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយអនឡាញរបស់កម្ពុជាពេលនេះ ត្រូវបានគ្របដណ្ដប់ ដោយក្រុមតូចមួយ នៃបុគ្គលដែលមានទំនាក់ទំនងស្និទ្ធនឹងរដ្ឋាភិបាលដោយដាក់កម្រិតលើទស្សនៈនយោបាយដែលបានបញ្ចេញនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ទៅជាគោលជំហរគាំទ្រដល់រដ្ឋាភិបាលទៅវិញ។ ការណ៍នេះក៏ដាក់កំហិតដល់អ្នកសារព័ត៌មានឯករាជ្យ និងសមត្ថភាពរបស់ពួកគេក្នុងការរាយការណ៍ព័ត៌មានឲ្យបានត្រឹមត្រូវដែរ។

តាមស្ថានភាពពេលនេះ មានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យតិចតួចណាស់ដែលនៅសល់បើកដំណើរការក្នុងកម្ពុជា។

ខណៈដែលការគំរាមកំហែងទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅតែបន្តសេរីភាពសារព័ត៌មាននៅតែបន្តធ្លាក់ចុះៗ ទាំងនេះបង្កើតឲ្យមានស្ថានភាពមួយដែលសាធារណជនមិនទទួលបានមានព័ត៌មានច្បាស់លាស់ ឬមានសិទ្ធិអំណាចក្នុងការសម្រេចចិត្តបោះឆ្នោតរបស់ពួកគេ។

នៅលើសន្ទស្សន៍សេរីភាពសារព័ត៌មានពិភពលោកឆ្នាំ ២០២៣ ជាសន្ទស្សន៍ឃ្លាំមើលដោយអង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (RSF) ដែលវាស់វែងកម្រិតសេរីភាពដែលមានសម្រាប់អ្នកសារព័ត៌មាននោះ កម្ពុជាជាប់ចំណាត់ថ្នាក់១៤៧ ក្នុងចំណោម ១៨០ ដោយធ្លាក់ចុះប្រាំថ្នាក់ពីចំណាត់ថ្នាក់១៤២ ក្នុងចំណោម ១៨០ នៅក្នុងសន្ទស្សន៍ឆ្នាំ ២០២២។

ភាពជាប់ពាក់ព័ន្ធនៃការរឹតត្បិត របស់រដ្ឋាភិបាលទៅលើដំណើរការប្រជាធិបតេយ្យ និង ការចូលរួមពលរដ្ឋនៅកម្ពុជា គឺគួរតែជាមូលហេតុចម្បងចំពោះការព្រួយបារម្ភ។ ដោយសារឥទ្ធិពលមិនសមាមាត្រនៃអ៊ីនធឺណិតនោះទើបសេរីភាពប្រព័ន្ធផ្សព្វផ្សាយអនឡាញមានសារៈសំខាន់ណាស់ក្នុងការតស៊ូដើម្បីការពារលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង សិទ្ធិសាធារណជនក្នុងការទទួលបានព័ត៌មានដែលគួរឲ្យទុកចិត្តបានក្នុងប្រទេសកម្ពុជា។

យោងតាមឯកសារផ្លូវការដែលខេមបូចាទទួលបាននៅថ្ងៃដដែលនោះរដ្ឋាភិបាលបានចោទប្រព័ន្ធផ្សព្វផ្សាយទាំងនោះ និង គេហទំព័រកំណត់ត្រា ថាបានផ្សាយព័ត៌មានដែលមានគោលបំណងធ្វើឱ្យមានការយល់ច្រឡំប៉ះពាល់ដល់កិត្តិយស និង កិត្យានុភាពរបស់រាជរដ្ឋាភិបាល និងមិនបានបំពេញលក្ខខណ្ឌក្នុងការធ្វើអាជីវកម្មនៅក្រសួងព័ត៌មាន។

ចំណាត់ការនេះបានធ្វើឡើងក្នុងបរិបទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។

ឆ្លើយតបទៅនឹងបទបញ្ជារបស់រដ្ឋាភិបាល លោក Rohit Mahajan ប្រធានផ្នែកទំនាក់ទំនងរបស់វិទ្យុអាស៊ីសេរីបានថ្កោលទោសយ៉ាងដាច់អហង្ការចំពោះចំណាត់ការនេះ ដោយបញ្ជាក់ថា វាជាការរំលោភបំពានយ៉ាងច្បាស់ក្រឡែតលើច្បាប់កម្ពុជា និង ជាការប៉ុនប៉ងពិនិត្យចាប់កំហុសលើលំហូរព័ត៌មានដោយសេរីនៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

*នៅលើគេហទំព័រកំណត់ត្រា អង្គការនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការផ្តល់ជូនពលរដ្ឋកម្ពុជានូវព័ត៌មានដែលពួកគេត្រូវការ ដើម្បីធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង។ នៅក្នុងសេចក្តីថ្លែងការណ៍មួយនៅលើ Twitter ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ គេហទំព័រកំណត់ត្រា បានជានាដល់សាធារណជនថា ខ្លួនកំពុងដោះស្រាយបញ្ហានេះ និង ស្វែងរកវិធីផ្សេង សម្រាប់អ្នកប្រើប្រាស់ដើម្បីអាចចូលប្រើទិន្នន័យ និង ព័ត៌មានស៊ីជម្រៅពីមូលដ្ឋានទិន្នន័យរបស់ខ្លួន។*

*ក្រសួងមហាផ្ទៃបានអះអាងថា គេហទំព័រកំណត់ត្រាថាមិនមានមូលដ្ឋានជាប្រភេទទិន្នន័យឡើយ វាមើលទៅដូចគេហទំព័រនេះមានមុខងារច្រើនជាប្រភេទកាសែតហើយមិនមានអាជ្ញាបណ្ណប្រព័ន្ធផ្សព្វផ្សាយចាំបាច់ដើម្បីដំណើរការទេ។*

*គេហទំព័រកំណត់ត្រា ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងការបិទវីអូឌី កាលពីខែកុម្ភៈ ដោយបង្ហាញពីការបន្តរឹតត្បិតជាគោលដៅទៅលើសេរីភាពសារព័ត៌មាននៅកម្ពុជា។*

*ចំណាត់ការនេះមិនមែនជាឧទាហរណ៍ដំបូង នៃការរឹតត្បិតទៅលើគេហទំព័រមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅកម្ពុជានោះទេ ។ ចំណាត់ការស្រដៀងគ្នានេះត្រូវបានធ្វើឡើងនៅមុនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៨នៅពេលដែលក្រសួងព័ត៌មានបានបញ្ជាឱ្យក្រុមហ៊ុនISP បិទការចូលទៅកាន់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង គេហទំព័រព័ត៌មានមួយចំនួន រួមទាំងវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) វិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) វិទ្យុអាស៊ីសេរី។ (RFA) កាសែតភ្នំពេញប៉ុស្តិ៍ និងគណបក្សសង្គ្រោះជាតិ។*

*រដ្ឋាភិបាលបានចោទថាអង្គភាពសារព័ត៌មានទាំងនេះបានប្រើប្រាស់ប្រភពពីបរទេសដើម្បីធ្វើឲ្យរាំងស្ទះដល់ការបោះឆ្នោត ដែលបានបំពានច្បាប់បោះឆ្នោត។ សរុបមក ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យចំនួន១៧អង្គភាពត្រូវបាន បិទគេហទំព័រ ។*

*សេរីភាពនៃការទទួលបានប្រព័ន្ធផ្សព្វផ្សាយព័ត៌មានគឺមានសារៈសំខាន់សម្រាប់លទ្ធិប្រជាធិបតេយ្យដែលកំពុងតែដំណើរការ។ ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ឱ្យអ្នកបោះឆ្នោតនូវព័ត៌មានត្រឹមត្រូវនិងគួរឱ្យទុកចិត្តដែលធ្វើឱ្យពួកគេធ្វើការសម្រេចចិត្តដោយទទួលបានព័ត៌មានច្បាស់លាស់ក្នុងអំឡុងពេលបោះឆ្នោត។*

*ការគំរាមកំហែងទៅលើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពសារព័ត៌មាននៅតែបន្តកើនឡើង ដែលឈានទៅដល់ការធ្លាក់ចុះនៃសេរីភាពសារព័ត៌មាននៅកម្ពុជាទាំងមូល។ កង្វះការទទួលបានព័ត៌មានដែលគួរឲ្យជឿទុកចិត្តគឺបានប៉ះពាល់ជាអវិជ្ជមានដល់សមត្ថភាពរបស់សាធារណជនក្នុងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការការបោះឆ្នោត។ ក្នុងអំឡុងពេលមុនការបោះឆ្នោត ការរឹតត្បិត នៅតែជាបញ្ហា ហើយត្រូវតែឃ្លាំមើលយ៉ាងដិតដល់។៚*

# ករណីសិក្សា៖ បញ្ហាប្រឈមរបស់ស្ថាប័នសារព័ត៌មានឯករាជ្យ និងអ្នកសារព័ត៌មាននៅកម្ពុជា

ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង អ្នកសារព័ត៌មានយល់ឃើញថា បរិយាកាសបច្ចុប្បន្នពិបាកធ្វើការណាស់ ជាពិសេសដោយសារប្រតិបត្តិការរបស់អង្គភាពផ្សព្វផ្សាយព័ត៌មានភាគច្រើនត្រូវបានបិទ ឬទិញយកដោយក្រុមគាំទ្ររដ្ឋាភិបាល។

ការយាយី គឺជារឿងកើតឡើងទូទៅចំពោះអ្នកសារព័ត៌មាន។ លោក លីបលីប អ្នកយកព័ត៌មាននៅវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) ដែលគាំទ្រដោយសហរដ្ឋអាមេរិកបាននិយាយថា "ខ្ញុំបានកត់សម្គាល់ឃើញថា អ្នកសារព័ត៌មានឯករាជ្យមិនត្រូវបានអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលឲ្យតម្លៃនោះទេ"។ លោកបន្តថា៖ «ការស្នើសុំព័ត៌មាន គឺពិបាកណាស់ ហើយជួនកាល អ្នកយកព័ត៌មានត្រូវគេគំហកដាក់។"

មន្ត្រីរដ្ឋាភិបាលបានចោទអ្នកសារព័ត៌មានឯករាជ្យថាបម្រើឲ្យនិន្នាការនយោបាយ ឬជនបរទេស។ ពេលចុះយកព័ត៌មាននៅតាមទីសាធារណៈ អាជ្ញាធរឃ្លាំមើល អ្នកសារព័ត៌មាន ថតរូបពួកគេ ហើយថែមទាំងហាមប្រាមមិនឲ្យរាយការណ៍ក្នុងករណីខ្លះដែរ។

លោកថា "វាមិនងាយស្រួលទេ ដើម្បីទទួលបានព័ត៌មានដែលគេចង់ដឹង។"

លើសពីនេះ ការញុះញង់នៅពេលនេះ គឺជាបទចោទប្រកាន់ដ៏ពេញនិយមមួយ ដើម្បីដាក់បទចោទលើអ្នកសារព័ត៌មាន សកម្មជនសង្គម និងនយោបាយ និងអ្នកដែលបញ្ចេញមតិអវិជ្ជមានអំពីសង្គមកម្ពុជា និងរដ្ឋាភិបាលជាទូទៅ។

ការបន្ថែមទៅលើកត្តាទាំងនេះ គឺជាការថយចុះនៃចំនួនអង្គភាពផ្សព្វផ្សាយឯករាជ្យ និង ចំនួនអ្នកសារព័ត៌មានដែលធ្វើការនៅទីនោះ។

យោងតាម កញ្ញា សុវណ្ណ ស្រីពេជ្រ អ្នកយកព័ត៌មានរបស់ ខេមបូចា ដែលជាអង្គភាពព័ត៌មានឯករាជ្យចុងក្រោយមួយនៅក្នុងកម្ពុជា បានអត្ថាធិប្បាយលើបទពិសោធន៍របស់នាងថា៖ ជួនកាល អាជ្ញាធរនឹងសាកសួរ[អ្នកព័ត៌មាន] ខណៈពួកគេពាក់ម៉ាស់ និង មួក ដូច្នេះវាមិនច្បាស់ថា ពួកគេពិតជាអាជ្ញាធរនោះទេ។ ពួកគេនឹងថតវីដេអូ ហើយចាប់យកមុខអ្នកសារព័ត៌មាន»។

ស្រីពេជ្រ បានបន្តថា បើអ្នកមកពីអង្គភាពផ្សព្វផ្សាយដែលរាយការណ៍ព័ត៌មានស៊ីជម្រៅ និង ស៊ើបអង្កេត គេ

*នឹងសាកសួរអ្នកច្រើន។ "គេសួរថា អ្នកជានរណា អ្នកមកពីណា ធ្វើការនៅទីណា?*

*ស្រីពេជ្រ បានបន្ថែមថា អ្នកសារព័ត៌មានស្ត្រីជួបប្រទះបញ្ហាប្រឈមច្រើនជាងអ្នកសារព័ត៌មានប្រុស គឺជារឿយៗ ប្រឈមមុខនឹងការយាយីផ្នែកភេទឱ្យក្នុងពេលកំពុងចុះយកព័ត៌មាន។ ក្រុមមួយ គឺបណ្ដាញអ្នកសារព័ត៌មានស្ត្រីកម្ពុជា(CFJ) ដែលជាបណ្ដាញអ្នកសារព័ត៌មានស្ត្រីជួបប្រជុំគ្នារៀងរាល់ខែ ដើម្បីនិយាយអំពីបទពិសោធន៍របស់ពួកគេ និងគាំទ្រគ្នាទៅវិញទៅមក។*

*ក្រុមតស៊ូមតិផ្នែកសារព័ត៌មាន និង ការបញ្ចេញមតិដោយសេរីមួយចំនួនបានបង្កើតអង្គការក្រៅរដ្ឋាភិបាល និង ក្រុមតស៊ូមតិផ្សេងទៀត។ លោកស្រី ឆន សុគន្ធា ដែលធ្វើការជាមួយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) បាននិយាយថា មធ្យោបាយមួយដើម្បីកែលម្អស្ថានការណ៍ គឺតាមរយៈការបង្កើនចំនួនប្រព័ន្ធផ្សព្វផ្សាយដែលអាចរកបាន ដើម្បីបង្កើនកន្លែងលំហសម្រាប់អ្នកសារព័ត៌មានដែលធ្វើការ និងដែលប្ដេជ្ញា។ រដ្ឋាភិបាលថ្មីដែលបង្កើតឡើងក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាឆ្នាំ ២០២៣ ក៏គួរតែបើកចំហលំហសម្រាប់សង្គមស៊ីវិល និង ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែរ ទើបប្រជាជនកម្ពុជាអាចប្រើប្រាស់សិទ្ធិរបស់គេដោយសេរី និងមិនមានការភ័យខ្លាច។*

*នៅពេលសុំឲ្យធ្វើអត្ថាធិប្បាយ លោក មាស សោភ័ណ្ឌ ដែលជាអ្នកនាំពាក្យក្រសួងព័ត៌មាននៅពេលនោះ បាននិយាយថា "សេរីភាពសារព័ត៌មាននៅកម្ពុជាត្រូវបានធានាដោយច្បាប់ស្ដីពីសារព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងស្មារតីនេះ អ្នកសារព័ត៌មាន ឬអ្នកដែលធ្វើការក្នុងវិស័យសារព័ត៌មាន មានសិទ្ធិពេញលេញក្នុងការបំពេញភារកិច្ចរបស់ខ្លួន និង រាយការណ៍ដោយសេរីនៅគ្រប់កន្លែង ដោយគ្មានការរឹតត្បិត ការតាមដាន និងការគំរាមកំហែង ដូចដែលមានចែងហើយ។ លោក សោភ័ណ្ឌ បច្ចុប្បន្នជាអ្នកនាំពាក្យលោកនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត។*

*សេរីភាពសារព័ត៌មាននៅកម្ពុជានៅតែជាបញ្ហាសំខាន់។ ការជម្នះលើចំណុចសំខាន់នេះ នឹងទាមទារឱ្យមានការបង្កើតបរិយាកាសនៃការសន្ទនាបើកចំហ និងកំណែទម្រង់ ក៏ដូចជាកិច្ចសហប្រតិបត្តិការរវាងអ្នកសារព័ត៌មានដែលមានបទពិសោធន៍ និងរដ្ឋាភិបាល។*

# ប្រវត្តិនៃការរឹតត្បិត តាមអនឡាញនៅកម្ពុជា

ទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញរបស់កម្ពុជាបានឆ្លងកាត់ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗកន្លងមកនេះ ដោយសារចំណាត់ការរបស់រដ្ឋាភិបាល។

នៅឆ្នាំ២០១៧ កាសែត ឌឹ ខេមបូឌា ដេលី ដែលជាអង្គភាពផ្សព្វផ្សាយឯករាជ្យ បានបង្ខំចិត្តបញ្ឈប់ប្រតិបត្តិការបោះពុម្ពរបស់ខ្លួន ដោយសារមូលហេតុបញ្ហារឿងពន្ធ។ មិនយូរប៉ុន្មាន រដ្ឋាភិបាលបានបញ្ជាឱ្យអ្នកផ្តល់សេវាអ៊ីនធឺណិត (ISP) នៅក្នុងប្រទេសរាំងខ្ទប់ការចូលទៅកាន់គេហទំព័ររបស់កាសែតនេះដែរ។

នៅក្នុងឆ្នាំ ២០១៨ រដ្ឋាភិបាលបានបិទការចូលប្រើប្រព័ន្ធផ្សព្វផ្សាយឯករាជ្យចំនួន ១៥អង្គភាពដទៃទៀត រួមទាំងគេហទំព័ររបស់គណបក្សសង្គ្រោះជាតិ ដែលត្រូវបានរំលាយដោយតុលាការ សំឡេងសហរដ្ឋអាមេរិក (VOA) សំឡេងប្រជាធិបតេយ្យ (VOD) និងវិទ្យុអាស៊ីសេរី (RFA)។ វិទ្យុអាស៊ីសេរី ក៏ត្រូវបង្ខំចិត្តបិទការិយាល័យនៅទីក្រុងភ្នំពេញដែរ។

លើសពីនេះទៅទៀត នៅឆ្នាំ ២០១៨ កាសែតភ្នំពេញប៉ុស្តិ៍បានបាត់បង់ឯករាជ្យភាពរបស់ខ្លួន ដោយសារកាសែតនេះត្រូវបានទិញដោយម្ចាស់ថ្មីដែលមានទំនាក់ទំនងស្និទ្ធនឹងមន្ត្រីរដ្ឋាភិបាល។

នៅដើមឆ្នាំ២០២៣ វិទ្យុសំឡេងប្រជាធិបតេយ្យ ដែលជាប្រព័ន្ធផ្សព្វផ្សាយឯករាជ្យចុងក្រោយបង្អស់របស់ប្រទេសនេះ ក៏ត្រូវបានរដ្ឋាភិបាលបិទដែរ។

លើសពីនេះទៅទៀត មុនដល់ពេលការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ ២០២៣ និយតករទូរគមនាគមន៍កម្ពុជា បានបញ្ជាឲ្យអ្នកផ្តល់សេវាអ៊ីនធឺណិត កាត់ផ្តាច់ការចូលប្រើក្នុងប្រទេសទៅកាន់គេហទំព័រ ឌឹ ខេមបូឌា ដេលី វិទ្យុអាស៊ីសេរី និងគេហទំព័រកំណត់ត្រាដែលទើបដាក់ឱ្យដំណើរការថ្មី និងគ្រប់គ្រងដោយ CCIM។ រដ្ឋាភិបាលក៏បានលុបអាជ្ញាបណ្ណរបស់អង្គភាពផ្សព្វផ្សាយជាភាសាខ្មែរចំនួនបីដែរ គឺសមាគមអ្នកសារព័ត៌មានកម្ពុជា អាស៊ាន គេហទំព័រ រស្មីកំពង់ចាម និង សារព័ត៌មានដំណឹងក្នុងស្រុក។ អង្គភាពសារព័ត៌មានទាំងបីរងការចោទប្រកាន់ថា «ប្រព្រឹត្តិកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរនិងមិនព្រមអនុវត្តតាមការអប់រំណែនាំរបស់ក្រសួង»។

បច្ចុប្បន្ននេះ ហ្វេសប៊ុក គឺជាវេទិកាអនឡាញដ៏សំខាន់របស់ប្រទេសនេះ និងជាប្រភពបឋមនៃព័ត៌មាន និងដំណឹង។ អ្នកប្រើប្រាស់ទទួលបានមាតិកាពីក្បួនដំណោះស្រាយបញ្ហារបស់ហ្វេសប៊ុក ដែលជាទូទៅលម្អៀងទៅយកមាតិកាដែលគេបង់លុយឲ្យជាផ្លូវការ។៚

# ទំនាក់ទំនង

+855 (0)23 88 23 11

communications@camboja.net

ផ្ទះលេខ១៩ ផ្លូវ៣៨៨ សង្កាត់ទួលស្វាយព្រៃ១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

www.camboja.net